ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



# ធនធានគម្របព្រៃឈើកម្ពុជា ឆ្នាំ២០១៦







ខែមីនា ឆ្នាំ២០១៨

**ក្រសួងបរិស្ថាន**

**អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ**

អគារមរតកតេជោ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់

ខណ្ឌចំការមន ភ្នំពេញ

<u>សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:</u>

Tel: ០១២ ៤៨៨ ៣៣៩,    Email: sophyra.sar@gmail.com

Tel: ០១៧ ៩៥៥ ៨១១,    Email: netnorint@gmail.com

ផលិតដោយ៖ ក្រុមការងារបច្ចេកទេសវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់

# អារម្ភកថា

ប្រទេសកម្ពុជាសម្បូរទៅដោយធនធានធម្មជាតិ។ ព្រៃឈើបានដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារថែរក្សាលំនឹងបរិស្ថាន ការកាត់បន្ថយការប្រែប្រួលអាកាសធាតុចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ។ ទន្ទឹមគ្នានេះបញ្ហាប្រឈមធំៗមួយចំនួននៅតែជាកង្វល់ដូចជាការថយចុះទំហំផ្ទៃដីព្រៃឈើ នាដំណាក់កាលចុងក្រោយនេះដែលបណ្តាលមកពីកំណើនតម្រូវការដីកសិកម្មស្របទៅនឹងកំណើនប្រជាពលរដ្ឋកើនឡើងជាលំដាប់និងការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចកសិកម្ម។ ស្ថិតក្នុងបរិបទនេះរាជរដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិទី៥ បានខិតខំរៀបចំកំណែទម្រង់ស៊ីជម្រៅលើវិស័យបរិស្ថាន ដាក់ស្តែងការផ្ទេរនិងទទួលតំបន់ព្រៃការពារ តំបន់អភិរក្ស តំបន់ព្រៃផ្តល់ផល និងដីសម្បទានសេដ្ឋកិច្ច រវាងក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សំដៅពង្រឹងការបែងចែកមុខងារគ្រប់គ្រងរបស់ស្ថាប័នរដ្ឋ ក្នុងការងារអភិវឌ្ឍន៍ និងការងារអភិរក្ស លើកកម្ពស់ប្រសិទ្ធិភាពក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការរស់នៅដោយចីរភាព។

តាមរយៈកំណែទម្រង់វិស័យគ្រប់គ្រងធនធានធម្មជាតិក្នុងអាណត្តិទី៥នេះ បច្ចុប្បន្នតំបន់ការពារធម្មជាតិត្រូវបានបង្កើនចំនួនឡើងដល់ ៥០តំបន់ និងបានដាក់បញ្ចូលបន្ថែមផ្ទៃដីរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ធ្វើឱ្យផ្ទៃដីតំបន់ការពារធម្មជាតិសរុបមានប្រមាណ៧,៥លានហិកតា ឬស្មើនឹង៤១ភាគរយនៃផ្ទៃដីប្រទេស។ ដូចនេះការធ្វើបច្ចុប្បន្នភាពធនធានគម្របព្រៃឈើឱ្យកាន់តែមានសុក្រឹតភាពខ្ពស់ស្របតាមការវិវត្តក្នុងកាលៈទេសៈបច្ចុប្បន្ន គឺជាការងារចាំបាច់មួយ។

គោលបំណងចម្បងនៃសៀវភៅនេះ គឺដើម្បីផ្តល់នូវព័ត៌មានជាក់លាក់អំពីធនធានគម្របព្រៃឈើទូទាំងប្រទេសក្នុងឆ្នាំ២០១៦ ជូនអ្នកសិក្សាស្រាវជ្រាវ និងសាធារណៈជនទូទៅដើម្បីបានជ្រាប និងប្រើប្រាស់ជាជំនួយក្នុងការរៀបចំផែនការអភិវឌ្ឍន៍ ការកំណត់គោលនយោបាយបរិស្ថាន ផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ការពារ និងអភិរក្សធនធានព្រៃឈើ និងជាប្រភពទិន្នន័យសកម្ម (Activity Data) សំខាន់ៗសម្រាប់បម្រើឱ្យការអនុវត្តសកម្មភាពក្នុងកម្មវិធីរេដបូកកម្ពុជា។ ទិន្នន័យដែលបានដាក់បង្ហាញជូនក្នុងសៀវភៅនេះ មានលក្ខណៈជានានូវតម្លាភាព ភាពពេញលេញ សង្គតិភាព និងសុក្រឹតភាពខ្ពស់ គោរពទៅតាមគោលការណ៍ណែនាំថ្មីៗបំផុតសម្រាប់វិស័យព្រៃឈើរបស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC)។ ទិន្នន័យទាំងនេះក៏ជាការបំពេញបន្ថែមផងដែរ ទៅលើកម្រងទិន្នន័យបម្រែបម្រួលគម្របព្រៃឈើ នៃប្រព័ន្ធតំបន់ការពារធម្មជាតិឆ្នាំ២០០៦-២០១៦ ដែលបានបោះពុម្ពកាលពីខែសីហា ឆ្នាំ២០១៧ កន្លងទៅ។

ក្នុងនាមជារដ្ឋមន្ត្រីក្រសួងបរិស្ថាន ខ្ញុំសូមកោតសរសើរដោយស្មោះចំពោះថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់នៃក្រសួងបរិស្ថាន ជាពិសេសក្រុមការងារបច្ចេកទេសប្រព័ន្ធព័ត៌មាន(REDD+) នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ សហការជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់

ដែលបានខិតខំជួយជ្រោមជ្រែងទាំងបច្ចេកទេស និងថវិកាក្នុងការរៀបចំកសាងសៀវភៅដ៏មានសារៈសំខាន់នេះរហូតបានសម្រេចជារូបរាងឡើង និងសូមប្រកាសដាក់ឱ្យប្រើប្រាស់ចាប់ពីពេលនេះតទៅ៕

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំនៃក្រសួងបរិស្ថានទាំងមូលដែលបានយកអស់កំលាំងកាយចិត្ត និងប្រាជ្ញាស្មារតី រៀបចំគោលនយោបាយផែនការយុទ្ធសាស្ត្រគ្រប់គ្រង ការពារ និងអភិរក្សធនធានព្រៃឈើ តំបន់ការពារធម្មជាតិ។ ក្នុងន័យនេះ សៀវភៅ **«ធនធានគម្របព្រៃឈើកម្ពុជាឆ្នាំ២០១៦»** បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ព័ត៌មានទិន្នន័យ សម្រាប់រៀបចំផែនការគ្រប់គ្រង ការពារ និងអភិរក្សប្រកបដោយនិរន្តភាព។

យើងខ្ញុំជាក្រុមការងារ ក៏សូមអនុញ្ញាតថ្លែងអំណរគុណ ជាពិសេសជូនចំពោះអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍រួមមាន អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ(FAO) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនប្រចាំកម្ពុជា(JICA) មូលនិធិភាពជាដៃគូកាបូនព្រៃឈើ(FCPF) និង វិទ្យាស្ថានស្រាវជ្រាវព្រៃឈើ និងផលិតផលព្រៃឈើ(FFPRI) នៃប្រទេសជប៉ុន ដែលបានចូលរួមសហការគាំទ្រក្នុងការរៀបចំបង្កើតសៀវភៅនេះឡើង។

យើងខ្ញុំក៏សង្ឃឹមយ៉ាងមុតមាំថា នឹងទទួលបានការគាំទ្រពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងមិត្តភក្តិបរទេសទាំងអស់ ប្រើប្រាស់ជាប្រយោជន៍ដល់ការអនុវត្តការងារប្រចាំថ្ងៃដែលអាចជួបប្រទះដោយថាហេតុណាមួយ និងអាចទុកជាឯកសារយោង សម្រាប់ប្រើប្រាស់ទៅថ្ងៃមុខ។ តាមរយៈនេះ យើងខ្ញុំសូមសំដែងសេចក្តីរីករាយ និងអំណរគុណទុកជាមុន នូវរាល់ការផ្តល់មតិយោបល់ត្រលប់វិញប្រកបដោយអត្ថន័យកែលម្អ ស្ថាបនា ដើម្បីក្រុមការងារមានលទ្ធភាពធ្វើការកែតម្រូវភាពខ្វះខាតរបស់ខ្លួន សម្រាប់ការផលិតសៀវភៅលើកក្រោយៗទៀត ឱ្យមានភាពកាន់តែល្អប្រសើរជាងនេះ។

ជាចុងបញ្ចប់យើងខ្ញុំសូមគោរពជូនពរ ឯកឧត្តមរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំទាំងអស់នៃក្រសួងបរិស្ថាន រួមទាំងមិត្តភក្តិបរទេស ជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា


ទំព័រ

| | | |
|---|---|---|
| អារម្ភកថា | | i |
| សេចក្តីថ្លែងអំណរគុណ | | iii |
| មាតិកា | | iv |

**ជំពូកទី ១**

**ព័ត៌មានទូទៅ**

| | | |
|---|---|---|
| ១.១ | សេចក្តីផ្តើម | ១ |
| ១.២ | គោលបំណង | ២ |
| ១.៣ | កម្រិតយោងព្រៃឈើ | ២ |

**ជំពូកទី ២**

**វិធីសាស្ត្រវាយតម្លៃធនធានគម្របព្រៃឈើ**

| | | |
|---|---|---|
| ២.១ | រូបភាពផ្កាយរណប | ៤ |
| ២.២ | វិធីសាស្ត្រចាត់ថ្នាក់ធនធានគម្របព្រៃឈើ | ៥ |
| ២.៣ | ការវាយតម្លៃកម្រិតជឿជាក់ | ៦ |

**ជំពូកទី ៣**

**លទ្ធផលវាយតម្លៃធនធានគម្របព្រៃឈើ**

| | | |
|---|---|---|
| ៣.១ | បច្ចុប្បន្នភាពធនធានគម្របព្រៃឈើ ឆ្នាំ២០១៦ | ៧ |
| | ក.លទ្ធផលវាយតម្លៃធនធានគម្របព្រៃឈើជាតិ | ៧ |
| | ខ.លទ្ធផលវាយតម្លៃធនធានគម្របព្រៃឈើសម្រាប់កម្មវិធីរេដបូក | ៩ |
| ៣.២ | ការប្រែប្រួលធនធានគម្របព្រៃឈើជាតិ ឆ្នាំ២០១៤-២០១៦ | ១១ |
| | ក.លទ្ធផលវាយតម្លៃការប្រែប្រួលធនធានគម្របព្រៃឈើជាតិ | ១១ |
| | ខ.លទ្ធផលវាយតម្លៃការប្រែប្រួលធនធានគម្របព្រៃឈើសម្រាប់កម្មវិធីរេដបូក | ១៣ |
| ៣.៣ | ការប្រែប្រួលធនធានគម្របព្រៃឈើជាតិ ឆ្នាំ១៩៦៥-២០១៦ | ១៥ |

**ជំពូកទី ៤**

**សន្និដ្ឋាន**

| | | |
|---|---|---|
| | សន្និដ្ឋាន | ១៨ |

## រូបភាព


| | | |
|---|---|---|
| រូបភាព១ | រូបភាពផ្កាយរណបប្រើប្រាស់សម្រាប់ចាត់ថ្នាក់ និងគាំទ្រដល់ការវាយតម្លៃកម្រិតជឿជាក់ធនធានគម្របព្រៃឈើឆ្នាំ២០១៦ | ៤ |
| រូបភាព២ | ដ្យាក្រាមបង្ហាញអំពីដំណាក់ការអនុវត្តបច្ចេកទេសវាយតម្លៃធនធានគម្របព្រៃឈើឆ្នាំ២០១៦ | ៥ |
| រូបភាព៣ | ទីតាំងចំណុចផ្ទៀងផ្ទាត់កម្រិតជឿជាក់ ទិន្នន័យគម្របព្រៃឈើឆ្នាំ២០១៦ | ៦ |
| រូបភាព៤ | ផែនទីធនធានគម្របព្រៃឈើជាតិឆ្នាំ២០១៦ (ព្រៃឈើជាតិ) | ៧ |
| រូបភាព៥ | អត្រាធនធានគម្របព្រៃឈើជាតិឆ្នាំ២០១៦ (ព្រៃឈើជាតិ) | ៩ |
| រូបភាព៦ | អត្រាធនធានគម្របព្រៃឈើ ឆ្នាំ២០១៦ (កម្មវិធីរេដបូក) | ៩ |
| រូបភាព៧ | ការប្រែប្រួលធនធានគម្របព្រៃឈើជាតិឆ្នាំ២០១៤-២០១៦(ព្រៃឈើជាតិ) | ១២ |
| រូបភាព៨ | ផែនទីការប្រែប្រួលធនធានគម្របព្រៃឈើជាតិ ឆ្នាំ២០១៤-២០១៦ (ព្រៃឈើជាតិ) | ១២ |
| រូបភាព៩ | ផែនទីការប្រែប្រួលធនធានគម្របព្រៃឈើ ឆ្នាំ២០១៤-២០១៦ (កម្មវិធីរេដបូក) | ១៤ |
| រូបភាព១០ | ការប្រែប្រួលធនធានគម្របព្រៃឈើ ឆ្នាំ២០០៦-២០១៦(កម្មវិធីរេដបូក) | ១៥ |
| រូបភាព១១ | អត្រាការប្រែប្រួលធនធានគម្របព្រៃឈើជាតិ ឆ្នាំ១៩៦៥-២០១៦ | ១៦ |
| រូបភាព១២ | ផែនទីការប្រែប្រួលធនធានគម្របព្រៃឈើជាតិ ឆ្នាំ២០០៦-២០១៦ (ព្រៃឈើជាតិ) | ១៧ |
| រូបភាព១៣ | ផែនទីការប្រែប្រួលធនធានគម្របព្រៃឈើ ឆ្នាំ២០០៦-២០១៦ (កម្មវិធីរេដបូក) | ១៧ |


## តារាង


| | | |
|---|---|---|
| តារាង១ | ស្ថិតិទិន្នន័យធនធានគម្របព្រៃឈើជាតិ ឆ្នាំ២០១៦ (ព្រៃឈើជាតិ) | ៨ |
| តារាង២ | ស្ថិតិទិន្នន័យធនធានគម្របព្រៃឈើ ឆ្នាំ២០១៦ (កម្មវិធីរេដបូក) | ១០ |
| តារាង៣ | : ស្ថិតិទិន្នន័យការប្រែប្រួលធនធានគម្របព្រៃឈើជាតិ ឆ្នាំ២០១៤-២០១៦ (ព្រៃឈើជាតិ) | ១១ |
| តារាង៤ | : ស្ថិតិទិន្នន័យការប្រែប្រួលធនធានគម្របព្រៃឈើ ឆ្នាំ២០១៤-២០១៦ (កម្មវិធីរេដបូក) | ១៣ |
| តារាង៥ | : ស្ថិតិទិន្នន័យការប្រែប្រួលធនធានគម្របព្រៃឈើ ឆ្នាំ២០០៦-២០១៦ (កម្មវិធីរេដបូក) | ១៤ |

# ឧបសម្ព័ន្ធ


| | | |
|---|---|---|
| ១ | និយមន័យព្រៃឈើ | ១៩ |
| ២ | តារាងចំណាត់ថ្នាក់ធនធានគម្របព្រៃឈើ ឆ្នាំ២០១៦ | ២០ |
| ៣ | ទិន្នន័យធនធានគម្របព្រៃឈើជាតិតាមបណ្តាខេត្ត ឆ្នាំ២០១៦ | ២១ |
| ៤ | ទិន្នន័យបម្រែបម្រួលប្រភេទព្រៃចន្លោះឆ្នាំ២០១៤-២០១៦ | ២២ |
| | ឯកសារយោង | ២៣ |

## ABBREVIATIONS

| **ACRONYM** | **FULL WORD** |
|---|---|
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| MoE | ក្រសួងបរិស្ថាន |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| GDANCP | អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ |
| FiA | រដ្ឋបាលជលផល |
| FA | រដ្ឋបាលព្រៃឈើ |
| NFP | កម្មវិធីព្រៃឈើជាតិ |
| NFMS | ប្រព័ន្ធត្រួតពិនិត្យតាមដានព្រៃឈើជាតិ |
| REDD | ការកាត់បន្ថយការបាត់បង់ការសឹករេចរិលព្រៃឈើ |
| MRV | ប្រព័ន្ធត្រួតពិនិត្យតាមដាន រាយការណ៍ និងផ្ទៀងផ្ទាត់ |
| FRL | កំរិតយោងព្រៃឈើ |
| SIS | ប្រព័ន្ធធានាសុវត្ថិភាព |
| FAO | អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការជប៉ុនប្រចាំកម្ពុជា |
| FCPF | មូលនិធិភាពជាដៃគូកាបូនព្រៃឈើ |
| FFPRI | វិទ្យាស្ថានស្រាវជ្រាវព្រៃឈើ និងផលិតផលព្រៃឈើជប៉ុន |
| ITTO | អង្គការព្រៃឈើត្រូពិចអន្តរជាតិ |
| MRC | គណៈកម្មការទន្លេមេគង្គ |
| FRM | ប្រព័ន្ធគ្រប់គ្រងធនធានព្រៃឈើ |
| GHG | ឧស្ម័នផ្ទះកញ្ចក់ |
| UNFCCC | អគ្គលេខាធិការនៃអនុសញ្ញាក្របខ័ណ្ឌស្តីពីការប្រែប្រួលអាកាសធាតុ |

# ជំពូកទី ១
# ព័ត៌មានទូទៅ

## ១.១ សេចក្តីផ្តើម

ក្រសួងបរិស្ថាន បានសហការផ្នែកបច្ចេកទេសជាមួយ អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ(FAO) គម្រោងភាពជាដៃគូកាបូនព្រៃឈើ (FCPF) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនប្រចាំកម្ពុជា (JICA) និងវិទ្យាស្ថានស្រាវជ្រាវព្រៃឈើ និងផលិតផលព្រៃឈើជប៉ុន (FFPRI)បានធ្វើការវាយតម្លៃធនធានគម្របដីព្រៃឈើ ដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានភូមិសាស្ត្រជាមួយរូបភាពផ្កាយរណបធ្វើការវាយតម្លៃជារៀងរាល់២ឆ្នាំម្តង។ ជាលទ្ធផលបង្ហាញថាអាត្រានៃការបាត់បង់ធនធានគម្របព្រៃឈើក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ មានអត្រាធ្លាក់ចុះគួរឱ្យកត់សំគាល់ ដោយរាជរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់វិស័យព្រៃឈើ ដោយដាក់ចេញនូវវិធានការចាំបាច់នានា ដើម្បីពង្រឹងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាពរួមមានៈ

១-ការត្រួតពិនិត្យសម្បទានដីសេដ្ឋកិច្ច ដោយសម្រេចលុបគោលការណ៍វិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុនមួយចំនួន

២-ការបង្កើតយន្តការទប់ស្កាត់ និងបង្រ្កាបបទល្មើសធនធានធម្មជាតិ

៣-ការកំណត់សមត្ថកិច្ចគ្រប់គ្រងការងារអភិរក្ស និងអភិវឌ្ឍន៍ឱ្យនៅដាច់ពីគ្នា ដោយផ្ទេរតំបន់ព្រៃការពារ និងអភិរក្សពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មកក្រសួងបរិស្ថាន ហើយផ្ទេរគម្រោងវិនិយោគអភិវឌ្ឍន៍ សម្បទានដីសេដ្ឋកិច្ចពីក្រសួងបរិស្ថាន ទៅក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ

៤-វេទិកាថ្នាក់ជាតិ ស្តីពីការការពារ និងអភិរក្សធនធានធម្មជាតិ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ និងនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧ ជាយន្តការចាំបាច់ដើម្បីពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធលើការងារការពារ និងអភិរក្សធនធានធម្មជាតិ

៥-សារាចរលេខ ០៥ សរណន ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីវិធានការចាំបាច់នានាក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ

៦-ការពង្រឹងសមត្ថភាព និងបង្កើនចំនួនមន្ត្រីឧទ្យានុរក្ស ដើម្បីបង្កើនប្រសិទ្ធភាពល្បាត និងការអនុវត្តច្បាប់នៅក្នុងតំបន់ការពារធម្មជាតិ

៧-ការផ្ទេរមុខងារ និងការទទួលខុសត្រូវទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រគ្រប់គ្រង ការពារ និងអភិរក្សធនធានធម្មជាតិ។

លើសពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនផ្ទៃដីតំបន់ការពារធម្មជាតិ តាមរយៈការបង្កើតតំបន់ការពារធម្មជាតិថ្មីៗមួយចំនួនបន្ថែម ធ្វើឱ្យតំបន់ការពារធម្មជាតិសរុបកើនឡើងចំនួន៥១

គ្របដណ្តប់លើផ្ទៃដីប្រមាណ ៧,៥ លានហិកតា។ ទិន្នន័យធនធានគម្របព្រៃឈើឆ្នាំ២០១៦នេះ រៀបចំផលិតដោយក្រុមការងារបច្ចេកទេសជាតិ (GDANCP/MoE, FA/MAFF, FIA/MAFF) និងត្រួតពិនិត្យផ្នែកបច្ចេកទេសដោយអ្នកជំនាញការអន្តរជាតិ FAO-UNREDD, JICA-CAMREDD និងសាកលវិទ្យាល័យអន្តរជាតិនានា។

## ១.២ គោលបំណង

គោលបំណងចម្បងនៃការសិក្សាវាយតម្លៃធនធានគម្របព្រៃឈើ គឺផ្តល់នូវព័ត៌មានជាក់លាក់អំពីធនធានគម្របព្រៃឈើទូទាំងប្រទេសដើម្បីរួមចំណែកក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងគោលនយោបាយ ផែនការយុទ្ធសាស្ត្រគ្រប់គ្រង ការពារ និងអភិរក្សធនធានព្រៃឈើ រួមទាំងផលិតទិន្នន័យសកម្ម (Activity Data) សម្រាប់គាំទ្រក្នុងការអនុវត្តកម្មវិធីរេដបូកកម្ពុជា។ ការវាយតម្លៃនេះមានគោលបំណងចម្បងចំនួន០៣ សំខាន់ៗគឺៈ

១.បច្ចុប្បន្នភាព និងផលិតទិន្នន័យផែនទីធនធានគម្របព្រៃឈើឆ្នាំ២០១៦

២.វាយតម្លៃបម្រែបម្រួលធនធានគម្របព្រៃឈើ ឆ្នាំ២០១៤-២០១៦ និងឆ្នាំ២០០៦-២០១៦

៣.សម្រាប់ប្រើប្រាស់ជាទិន្នន័យគោលក្នុងការរៀបចំយុទ្ធសាស្ត្រនិងផែនការសកម្មភាពគ្រប់គ្រងធនធានព្រៃឈើកម្ពុជា និងសម្រាប់អនុវត្តកម្មវិធីរេដបូកកម្ពុជា។

## ១.៣ កម្រិតយោងព្រៃឈើ

យោងតាមសេចក្តីសម្រេច4/CP.15, 1/CP.16, 12/CP.17, 13/CP.19 កម្ពុជាបានដាក់ឯកសាររបាយការណ៍ផ្អែកលើគោលការណ៍ស្ម័គ្រចិត្តដាក់ជូនទៅ អនុសញ្ញាក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ធ្វើការពិចារណាទទួលយកនូវរបាយការណ៍កម្រិតយោងព្រៃឈើ (FRL) លើកដំបូងនេះ។ នៅក្នុងរបាយការណ៍នេះ យើងផ្តល់សេចក្តីសង្ខេបអំពីប្រភេទទិន្នន័យ និងវិធីសាស្ត្រយកមកប្រើប្រាស់ សម្រាប់ការរៀបចំបង្កើតកម្រិតយោងព្រៃឈើ (FRL) លើកដំបូងរបស់កម្ពុជា។ ព័ត៌មានដែលបានបង្ហាញជូននេះ មានគោលដៅជានាតម្លាភាព ភាពពេញលេញ សង្គតិភាព និងសុក្រឹតភាព និងគោរពទៅតាមការណែនាំបច្ចេកទេស របស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) (IPCC, 2003a, 2003b, 2006a, 2006b)។ ឯកសាររបាយកាណ៍ (FRL) នេះមានគោលបំណងជាក់លាក់ ក្នុងការស្វែងរកឱកាសទទួលបាននូវការទូទាត់ផ្អែកតាមលទ្ធផល (RBP) ស្តែងចេញពីការអនុវត្តកម្មវិធីរេដបូកកម្ពុជា។

ប្រទេសកម្ពុជាមានទំហំផ្ទៃដីសរុប ១៨១,០៣៥គ.ម$^{២}$ កម្ពុជាត្រូវបានចាត់ចូលជាប្រទេសអភិវឌ្ឍន៍តិចតួច និងមានប្រាក់ចំណូលទាប។ ដោយសារសន្តិភាព និងស្ថិរភាពក្នុងអំឡុងប៉ុន្មានទសវត្សរ៍កន្លងមកនេះបាននាំមកនូវកំណើនសេដ្ឋកិច្ចជាលំដាប់ក្នុងអត្រាជាមធ្យមរវាង៧ និង១០ភាគរយ ចាប់តាំងពីឆ្នាំ ១៩៩៨មក ដែលនាំឲ្យមានការកាត់បន្ថយភាពក្រីក្រគួរឱ្យកត់សំគាល់ ប៉ុន្តែ

ទន្ទឹមនឹងនេះ ក៏បានបង្កើនសម្ពាធខ្លាំងមកលើធនធានធម្មជាតិរបស់ប្រទេសនេះផងដែរ។ ទោះជាយ៉ាងណា កម្ពុជានៅតែអាចរក្សាបាននូវ អត្រាធនធានគម្របព្រៃឈើខ្ពស់ជាបង្គួរ ដែលនៅតែជាប្រទេសមួយដែលមានអត្រាគម្របព្រៃឈើខ្ពស់នៅអាស៊ីអាគ្នេយ៍។ ទោះបីជាបច្ចុប្បន្នធនធានគម្របព្រៃឈើកម្ពុជានៅមានអត្រាខ្ពស់ក៏ដោយ ក៏ប្រទេសនេះបានបាត់បង់ផ្ទៃដីធនធានគម្របព្រៃឈើយ៉ាងច្រើនគួរឲ្យកត់សំគាល់ក្នុងអំឡុងពេលពីរទសវត្សរ៍ចុងក្រោយនេះ ហើយល្បឿននៃការប្រើប្រាស់ដី និងការបំលែងដីព្រៃឈើក៏បានកើនឡើងផងដែរ។

លទ្ធផលបឋមនៃកម្រិតយោងព្រៃឈើកម្ពុជាបានបង្ហាញថាបរិមាណស្រូប និងបញ្ចេញឧស្ម័នកាបូនិកសរុបមធ្យមប្រចាំឆ្នាំ ៧៨.៩៥៣.៩៥១ tCO2/ឆ្នាំ ដោយផ្អែកលើកម្រិតបំភាយយោងមធ្យមប្រចាំឆ្នាំពីឆ្នាំ២០០៦-២០១៤ *(ប្រភព៖ឯកសារបឋមនៃកម្រិតយោងព្រៃឈើកម្ពុជា ២០១៦)*។

# ជំពូកទី ២

## វិធីសាស្ត្រវាយតម្លៃធនធានគម្របព្រៃឈើ

### ២.១ រូបភាពផ្កាយរណប

ការវាយតម្លៃធនធានគម្របព្រៃឈើឆ្នាំ២០១៦ បានប្រើប្រាស់រូបភាពផ្កាយរណបប្រភេទផ្សេងៗគ្នារួមមានៈ

**ក.**ផ្កាយរណបប្រភេទ Landsat 8 របស់សហរដ្ឋអាមេរិក ត្រូវបានយកមកប្រើប្រាស់សម្រាប់ធ្វើការវាយតម្លៃ និងចាត់ថ្នាក់ធនធានគម្របព្រៃឈើឆ្នាំ២០១៦។ ក្រុមការងារបច្ចេកទេសប្រព័ន្ធព័ត៌មានភូមិសាស្ត្ររដេបូកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិង អភិរក្សធម្មជាតិ បានធ្វើការទាញយក និងជ្រើសរើសរូបភាពផ្កាយរណបចំនួន៥២ផ្ទាំង ពីគេហទំព័រ USGS សម្រាប់ធ្វើការវាយតម្លៃ និងចាត់ថ្នាក់ធនធានគម្របព្រៃឈើឆ្នាំ២០១៦ ចាប់ពីដើមខែតុលា ឆ្នាំ២០១៥ រហូតដល់ខែឧសភា ឆ្នាំ២០១៦។

**ខ.**រូបភាពផ្កាយរណបប្រភេទ Sentinel-2 (ឆ្នាំ២០១៦) SPOT5(ឆ្នាំ២០១៦) និងរូបភាពផ្កាយរណបប្រភេទ Rapid Eye (ឆ្នាំ២០១៥ និងឆ្នាំ២០១៦) ប្រើប្រាស់សម្រាប់គាំទ្រដល់ការវាយតម្លៃកម្រិតជឿជាក់នៃលទ្ធផល ការចាត់ថ្នាក់ធនធានគម្របព្រៃឈើឆ្នាំ២០១៦ និងផែនទីបម្រែបម្រួលធនធានគម្របព្រៃឈើឆ្នាំ២០១៤-២០១៦។




*ចំណាំៈខ្សែបន្ទាត់ព្រំដែននៃផែនទីនេះពុំមានតម្លៃផ្លូវការជាអន្តរជាតិឡើយ ។*

**រូបភាព១ :** រូបភាពផ្កាយរណបប្រើប្រាស់សម្រាប់ចាត់ថ្នាក់ និងគាំទ្រដល់ការវាយតម្លៃកម្រិតជឿជាក់ធនធានគម្របព្រៃឈើឆ្នាំ២០១៦

## ២.២ វិធីសាស្ត្រចាត់ថ្នាក់ធនធានគម្របព្រៃឈើ

វិធីសាស្ត្រនៃការបែងចែកព្រំប្រទល់ប្រភេទព្រៃឈើតាមរយៈ Segmentation និងវិធីសាស្ត្រ Principle Component Analysis ដែលវាយតម្លៃបឋមលើការប្រែប្រួលធនធានគម្របព្រៃឈើឆ្នាំ២០១៤-២០១៦ ត្រូវបានប្រើប្រាស់សម្រាប់វាយតម្លៃគម្របព្រៃឈើឆ្នាំ២០១៦ ដោយធ្វើការចាត់ថ្នាក់សរុបចំនួន២២ចំណាត់ថ្នាក់ ក្នុងនោះចំណាត់ថ្នាក់គម្របព្រៃឈើមានចំនួន១៣ចំណាត់ថ្នាក់ និងដីពុំមានគម្របព្រៃឈើត្រូវបានបែងចែកចំនួន០៩ចំណាត់ថ្នាក់ ដោយកំណត់យកមាត្រដ្ឋានជាអប្បបរមាក្នុងការចាត់ថ្នាក់ចំនួន៥ហិកតា។ ជំហាននៃការវាយតម្លៃធនធានគម្របព្រៃឈើឆ្នាំ២០១៦ មានបង្ហាញជូនក្នុងដ្យាក្រាមខាងក្រោម:




**រូបភាព២ :** ដ្យាក្រាមបង្ហាញអំពីដំណាក់ការអនុវត្តបច្ចេកទេសវាយតម្លៃធនធានគម្របព្រៃឈើ ឆ្នាំ២០១៦

## ២.៣ ការវាយតម្លៃកម្រិតជឿជាក់

ការវាយតម្លៃកម្រិតជឿជាក់ គឺជាជំហានមួយធ្វើឡើងសម្រាប់ផ្ទៀងផ្ទាត់លទ្ធផលនៃការចាត់ថ្នាក់វាយតម្លៃធនធានគម្របព្រៃឈើ ដើម្បីបញ្ជាក់ពីសុក្រឹតភាពនៃប្រភេទចំណាត់ថ្នាក់នីមួយៗ។ ការវាយតម្លៃកម្រិតជឿជាក់ ទិន្នន័យធនធានគម្របព្រៃឈើធ្វើឡើងជា២ជំហានផ្សេងគ្នា ដោយធ្វើការចុះប្រមូលព័ត៌មានទិន្នន័យទីវាលជាក់ស្តែង និងផ្ទៀងផ្ទាត់ទិន្នន័យរូបភាពផ្កាយរណប RapidEye, SPOT5, Sentinel-2 និងជាមួយរូបភាព Google earth សម្រាប់ធ្វើការផ្ទៀងផ្ទាត់ចំណាត់ថ្នាក់ព្រៃឈើ ដោយមានចំណុចផ្ទៀងផ្ទាត់សរុបចំនួន១៦៥១ចំណុចគ្របដណ្តប់លើ២៥ខេត្ត-ក្រុង ទូទាំងប្រទេស។




**រូបភាព៣ :** ទីតាំងចំណុចផ្ទៀងផ្ទាត់កម្រិតជឿជាក់ ទិន្នន័យគម្របព្រៃឈើឆ្នាំ២០១៦

ការវាយតម្លៃកម្រិតជឿជាក់ត្រូវបានធ្វើឡើង ដោយសហការរវាងអ្នកបច្ចេកទេសជាតិ និងអន្តរជាតិ FAO-UNREDD, JICA-CAMREDD និងសាកលវិទ្យាល័យអន្តរជាតិនានា ដោយទទួលបានលទ្ធផលវាយតម្លៃស្មើនឹង៨៧,៤៨% សម្រាប់ទិន្នន័យធនធានគម្របព្រៃឈើឆ្នាំ២០១៦។

ដោយឡែក ចំពោះលទ្ធផលវាយតម្លៃកម្រិតជឿជាក់ នៃទិន្នន័យប្រែប្រួលធនធានគម្របព្រៃឈើក្នុងអំឡុងឆ្នាំ២០១៤-២០១៦ ទទួលបានលទ្ធផលស្មើនឹង៩០%។

# ជំពូកទី ៣

## លទ្ធផលការវាយតម្លៃធនធានគម្របព្រៃឈើ

### ៣.១ បច្ចុប្បន្នភាពធនធានគម្របព្រៃឈើឆ្នាំ២០១៦

#### ក.លទ្ធផលវាយតម្លៃធនធានគម្របព្រៃឈើជាតិ

តាមការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០១៦ ជាលទ្ធផលបានបង្ហាញថា ផ្ទៃដីព្រៃឈើមានប្រមាណ **៨.៧៤២.៤០១ ហិកតា** ស្មើនឹង៤៨,១៤% ធៀបនឹងផ្ទៃដីសរុបទូទាំងប្រទេស (លទ្ធផលនៃការវាយតម្លៃនេះរួមបញ្ចូលទាំងផ្ទៃដីចម្ការកៅស៊ូ ចម្ការដូងប្រេង និងដំណាំហូបផ្លែដទៃទៀត) ដូចមានបង្ហាញក្នុងផែនទី និងតារាងស្ថិតិខាងក្រោមៈ




**រូបភាព៤** : ផែនទីធនធានគម្របព្រៃឈើឆ្នាំ២០១៦ (ព្រៃឈើជាតិ)

**តារាង១: ស្ថិតិទិន្នន័យធនធានគម្របព្រៃឈើឆ្នាំ២០១៦(ព្រៃឈើជាតិ)**

| ល.រ | ប្រភេទចំណាត់ថ្នាក់ | ផ្ទៃដី | |
|---|---|---|---|
| | | ហិកតា | ភាគរយ (%) |
| ១ | ព្រៃស្រោង | ២.៨៦១.២៣៣ | ១៥,៧៦ |
| ២ | ព្រៃពាក់កណ្តាលស្រោង | ១.០៧១.៩៤៧ | ៥,៩០ |
| ៣ | ព្រៃល្បោះ | ៣.៣៣៦.៣៤៩ | ១៨,៣៧ |
| ៤ | ព្រៃលិចទឹក | ៤៧៧.៨១៣ | ២,៦៣ |
| ៥ | ព្រៃដុះឡើងវិញ | ១៩៦.៨៤២ | ១,០៨ |
| ៦ | ព្រៃឫស្សី | ១២៥.៣៩៨ | ០,៦៩ |
| ៧ | ព្រៃកោងកាង | ៣១.២២៦ | ០,១៧ |
| ៨ | ព្រៃស្នាច់ | ២៥.៩០៦ | ០,១៤ |
| ៩ | ព្រៃស្រល់ | ៨.១៩៥ | ០,០៥ |
| ១០ | ចម្ការស្រល់ | ៣.៨៧០ | ០,០២ |
| ១១ | ចម្ការឈើដាំ | ៤៣.១២២ | ០,២៤ |
| ១២ | ចម្ការដូងប្រេង | ៥១.២៧៦ | ០,២៨ |
| ១៣ | ចម្ការកៅស៊ូ | ៥០៩.២២៤ | ២,៨០ |
| **សរុបផ្ទៃដីគម្របព្រៃឈើ** | | **៨.៧៤២.៤០១** | **៤៨,១៤** |
| ១៤ | វាលស្មៅ | ៣៤១.១៣២ | ១,៨៨ |
| ១៥ | ចម្ការ | ៣.០១៧.៤៣៥ | ១៦,៦២ |
| ១៦ | ដីស្រែ | ៤.២២១.៤០៧ | ២៣,២៤ |
| ១៧ | ថ្ម | ១.១០០ | ០,០១ |
| ១៨ | ខ្សាច់ | ៤១.២៤៥ | ០,២៣ |
| ១៩ | ភូមិ | ៣៥២.៩៨៧ | ១,៩៤ |
| ២០ | ទីប្រជុំជន | ៤២.៩៣០ | ០,២៤ |
| ២១ | ផ្ទៃទឹក | ៧៨៣.៨៦០ | ៤,៣២ |
| ២២ | ព្រៃគុម្ពោត | ៦១៦.១៧៧ | ៣,៣៩ |
| **សរុបផ្ទៃដីពុំមានគម្របព្រៃឈើ** | | **៩.៤១៨.២៧៣** | **៥១,៨៦** |
| **ផ្ទៃដីសរុបរួម** | | **១៨.១៦០.៦៧៤** | **១០០** |




**រូបភាព៥** : អត្រាធនធានគម្របព្រៃឈើឆ្នាំ២០១៦ (ព្រៃឈើជាតិ)

**ខ.លទ្ធផលវាយតម្លៃធនធានគម្របព្រៃឈើសម្រាប់កម្មវិធីរេដបូក**

ធនធានគម្របព្រៃឈើឆ្នាំ២០១៦ គ្របដណ្តប់លើផ្ទៃដីព្រៃឈើប្រមាណ **៨.១៨១.៩០១ ហិកតា** ស្មើនឹង **៤៥,០៥%** ធៀបនឹងផ្ទៃដីសរុបទូទាំងប្រទេស ដូចមានបង្ហាញក្នុងក្រាហ្វិក និងតារាងស្ថិតិខាងក្រោម:




**រូបភាព៦** : អត្រាធនធានគម្របព្រៃឈើឆ្នាំ២០១៦(កម្មវិធីរេដបូក)

**តារាង២ :** ស្ថិតិទិន្នន័យធនធានគម្របព្រៃឈើឆ្នាំ២០១៦ (កម្មវិធីវេដបូក)

| ល.រ | ប្រភេទចំណាត់ថ្នាក់ | ផ្ទៃដី | |
|---|---|---|---|
| | | ហិកតា | ភាគរយ(%) |
| ១ | ព្រៃស្រោង | ២.៨៦១.២៣៣ | ១៥,៧៦ |
| ២ | ព្រៃពាក់កណ្តាលស្រោង | ១.០៧១.៩៤៧ | ៥,៩០ |
| ៣ | ព្រៃល្បោះ | ៣៣៣.៦៣៤៩ | ១៨,៣៧ |
| ៤ | ព្រៃលិចទឹក | ៤៧៧.៨១៣ | ២,៦៣ |
| ៥ | ព្រៃដុះឡើងវិញ | ១៩៦.៨៤២ | ១,០៨ |
| ៦ | ព្រៃឬស្សី | ១២៥.៣៩៨ | ០,៦៩ |
| ៧ | ព្រៃកោងកាង | ៣១.២២៦ | ០,១៧ |
| ៨ | ព្រៃស្នាច់ | ២៥.៩០៦ | ០,១៤ |
| ៩ | ព្រៃស្រល់ | ៨.១៩៥ | ០,០៥ |
| ១០ | ចម្ការស្រល់ | ៣.៨៧០ | ០,០២ |
| ១១ | ចម្ការឈើដាំ | ៤៣.១២២ | ០,២៤ |
| **សរុបផ្ទៃដីគម្របព្រៃឈើ** | | **៨.១៨១.៩០១** | **៤៥,០៥** |
| ១២ | ចម្ការដូងប្រេង | ៥១.២៧៦ | ០,២៨ |
| ១៣ | ចម្ការកៅស៊ូ | ៥០៩.២២៤ | ២,៨០ |
| ១៤ | វាលស្មៅ | ៣៤១.១៣២ | ១,៨៨ |
| ១៥ | ចម្ការ | ៣.០១៧.៤៣៥ | ១៦,៦២ |
| ១៦ | ដីស្រែ | ៤.២២១.៤០៧ | ២៣,២៤ |
| ១៧ | ថ្ម | ១.១០០ | ០,០១ |
| ១៨ | ខ្សាច់ | ៤១.២៤៥ | ០,២៣ |
| ១៩ | ភូមិ | ៣៥២.៩៨៧ | ១,៩៤ |
| ២០ | ទីប្រជុំជន | ៤២.៩៣០ | ០,២៤ |
| ២១ | ផ្ទៃទឹក | ៧៨៣.៨៦០ | ៤,៣២ |
| ២២ | ព្រៃគុម្ពោត | ៦១៦.១៧៧ | ៣,៣៩ |
| **សរុបផ្ទៃដីពុំមានគម្របព្រៃឈើ** | | **៩.៩៧៨.៧៧៣** | **៥៤,៩៥** |
| **សរុបផ្ទៃដីរួម** | | **១៨.១៦០.៦៧៤** | **១០០** |

## ៣.២ ការប្រែប្រួលធនធានគម្របព្រៃឈើក្នុងអំឡុងឆ្នាំ២០១៤-២០១៦

### ក.លទ្ធផលវាយតម្លៃការប្រែប្រួលធនធានគម្របព្រៃឈើជាតិ

អត្រាប្រែប្រួលធនធានគម្របព្រៃឈើឆ្នាំ២០១៤-២០១៦ បានបង្ហាញថាមានការប្រែប្រួលពី **៤៩,៤៨%** នៅឆ្នាំ២០១៤ មកត្រឹម **៤៨,១៤%** នៅឆ្នាំ២០១៦ ដោយមានអត្រាប្រែប្រួលជាមធ្យមប្រចាំឆ្នាំ **០,៦៧%** ស្មើនឹង **១២១,៣២៨ហិកតា** ធៀបនឹងផ្ទៃដីសរុបទូទាំងប្រទេស។

**តារាង៣ :** ស្ថិតិទិន្នន័យការប្រែប្រួលធនធានគម្របព្រៃឈើ ឆ្នាំ២០១៤-២០១៦ (ព្រៃឈើជាតិ)

| ល.រ | ប្រភេទចំណាត់ថ្នាក់ | ផ្ទៃដីគម្របព្រៃឈើ | | | | ការប្រែប្រួល | |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៤ | | ឆ្នាំ២០១៦ | | ២០១៤-២០១៦ | |
| | | ហិកតា | ភាគរយ% | ហិកតា | ភាគរយ% | ហិកតា | ភាគរយ% |
| ១ | ព្រៃស្រោង | ២.៩៧៣.៩០៣ | ១៦,៣៨ | ២.៨៦១.២៣៣ | ១៥,៧៦ | -១១២.៦៧០ | -០,៦២ |
| ២ | ព្រៃពាក់កណ្ដាលស្រោង | ១.១០៨.៣២០ | ៦,១០ | ១.០៧១.៩៤៧ | ៥,៩០ | -៣៦.៣៧៣ | -០,២០ |
| ៣ | ព្រៃល្បោះ | ៣.៤៨០.៥៣២ | ១៩,១៧ | ៣.៣៣៦.៣៤៩ | ១៨,៣៧ | -១៤៤.១៨៣ | -០,៨០ |
| ៤ | ព្រៃលិចទឹក | ៤៨១.០៧៨ | ២,៦៥ | ៤៧៧.៨១៣ | ២,៦៣ | -៣.២៦៥ | -០,០២ |
| ៥ | ព្រៃដុះឡើងវិញ | ២២៨.៥៦០ | ១,២៦ | ១៩៦.៨៤២ | ១,០៨ | -៣១.៧១៨ | -០,១៨ |
| ៦ | ព្រៃឫស្សី | ១៣០.៦៧៨ | ០,៧២ | ១២៥.៣៩៨ | ០,៦៩ | -៥,២៨០ | ០,០៣ |
| ៧ | ព្រៃកោងកាង | ៣៣.០០២ | ០,១៨ | ៣១.២២៦ | ០,១៧ | ១,៧៧៦ | ០,០១ |
| ៨ | ព្រៃស្នាប់ | ២៥.៩០៦ | ០,១៤ | ២៥.៩០៦ | ០,១៤ | ០ | -០,០០ |
| ៩ | ព្រៃស្រល់ | ៨.១៩៦ | ០,០៥ | ៨.១៩៥ | ០,០៥ | -១ | ០,០០ |
| ១០ | ចម្ការស្រល់ | ៣.៧០៩ | ០,០២ | ៣.៨៧០ | ០,០២ | ១៦០ | ០,០០ |
| ១១ | ចម្ការឈើដាំ | ៤៤.២៨៩ | ០,២៤ | ៤៣.១២២ | ០,២៤ | -១,១៦៧ | ០,០០ |
| ១២ | ចម្ការដូងប្រេង | ៣៣.២៩៧ | ០,១៨ | ៥១,២៧៦ | ០,២៨ | ១៧,៩៧៩ | ០,០៨ |
| ១៣ | ចម្ការកៅស៊ូ | ៤៣៣.៦៩៤ | ២,៣៩ | ៥០៩,២២៤ | ២,៨០ | ៧៥,៥៣០ | ០,៤១ |
| **សរុបផ្ទៃដីគម្របព្រៃឈើ** | | **៨.៩៨៥.១៦៤** | **៤៩,៤៨** | **៨.៧៤២.៤០១** | **៤៨,១៤** | **-២៤២,៧៦៤** | **-១,៣៤** |
| **សរុបផ្ទៃដីពុំមានគម្របព្រៃឈើ** | | **៩.១៧៥.៥១០** | **៥០,២២** | **៩.៤១៨.២៧៣** | **៥១,៨៦** | **២៤២,៧៦៤** | **១,៣៤** |
| **ផ្ទៃដីសរុបរួម** | | **១៨.១៦០.៦៧៤** | **១០០** | **១៨.១៦០.៦៧៤** | **១០០** | | |




**រូបភាព៧:** ការប្រែប្រួលធនធានគម្របព្រៃឈើឆ្នាំ២០១៤-២០១៦ (ព្រៃឈើជាតិ)

តាមរយៈក្រាហ្វិកខាងលើបង្ហាញថា ក្នុងអំឡុងឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦ ប្រភេទព្រៃឈើដែលមានការផ្លាស់ប្ដូរច្រើនជាងគេ គឺប្រភេទព្រៃល្បោះ ដែលមានអត្រាថយចុះ០,៨០% បន្ទាប់មកគឺប្រភេទព្រៃស្រោងដែលមានអត្រាថយចុះ០,៦២% ប្រភេទព្រៃពាក់កណ្ដាលស្រោងថយចុះ០,២០% និងព្រៃដុះឡើងវិញក៏មានអត្រាថយចុះ០,១៨% ផងដែរ។




**រូបភាព៨ :** ផែនទីការប្រែប្រួលធនធានគម្របព្រៃឈើជាតិ ឆ្នាំ២០១៤-២០១៦ (ព្រៃឈើជាតិ)

## ខ.លទ្ធផលវាយតម្លៃការប្រែប្រួលធនធានគម្របព្រៃឈើសម្រាប់កម្មវិធីរេដបូក

អត្រាប្រែប្រួលធនធានគម្របព្រៃឈើឆ្នាំ២០១៤-២០១៦ បានបង្ហាញថាមានការប្រែប្រួលពី **៤៦,៩០%** នៅឆ្នាំ២០១៤ មកត្រឹម **៤៥,០៥%** នៅឆ្នាំ២០១៦ ដោយមានអត្រាប្រែប្រួលជាមធ្យមប្រចាំឆ្នាំ **០,៩២%** ស្មើនឹង **១៦៨,១៣៦ ហិកតា** ធៀបនឹងផ្ទៃដីសរុបទូទាំងប្រទេស។ លទ្ធផលលម្អិតបង្ហាញជូនដូចមានក្នុងតារាងស្ថិតិ និងផែនទីខាងក្រោមៈ

**តារាង៤** : ស្ថិតិទិន្នន័យការប្រែប្រួលធនធានគម្របព្រៃឈើឆ្នាំ២០១៤-២០១៦ (កម្មវិធីរេដបូក)

| ល.រ | ប្រភេទចំណាត់ថ្នាក់ | ផ្ទៃដីគម្របព្រៃឈើ | | | | ការប្រែប្រួល | |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៤ | | ឆ្នាំ២០១៦ | | ២០១៤-២០១៦ | |
| | | ហិកតា | ភាគរយ% | ហិកតា | ភាគរយ% | ហិកតា | ភាគរយ% |
| ១ | ព្រៃស្រោង | ២.៩៧៣.៩០៣ | ១៦,៣៨ | ២.៨៦១.២៣៣ | ១៥,៧៦ | -១១២.៦៧០ | -០,៦២ |
| ២ | ព្រៃពាក់កណ្ដាលស្រោង | ១.១០៨.៣២០ | ៦,១០ | ១.០៧១.៩៤៧ | ៥,៩០ | -៣៦.៣៧៣ | -០,២០ |
| ៣ | ព្រៃល្បោះ | ៣.៤៨០.៥៣២ | ១៩,១៧ | ៣.៣៣៦.៣៤៩ | ១៨,៣៧ | -១៤៤.១៨៣ | -០,៨០ |
| ៤ | ព្រៃលិចទឹក | ៤៨១.០៧៨ | ២,៦៥ | ៤៧៧.៨១៣ | ២,៦៣ | -៣.២៦៥ | -០,០២ |
| ៥ | ព្រៃដុះឡើងវិញ | ២២៨.៥៦០ | ១,២៦ | ១៩៦.៨៤២ | ១,០៨ | -៣១.៧១៨ | -០,១៨ |
| ៦ | ព្រៃឫស្សី | ១៣០.៦៧៨ | ០,៧២ | ១២៥.៣៩៨ | ០,៦៩ | -៥,២៨០ | ០,០៣ |
| ៧ | ព្រៃកោងកាង | ៣៣.០០២ | ០,១៨ | ៣១.២២៦ | ០,១៧ | ១,៧៧៦ | -០,០១ |
| ៨ | ព្រៃស្នាច់ | ២៥.៩០៦ | ០,១៤ | ២៥.៩០៦ | ០,១៤ | ០ | ០,០០ |
| ៩ | ព្រៃស្រល់ | ៨.១៩៦ | ០,០៥ | ៨.១៩៥ | ០,០៥ | -១ | ០,០០ |
| ១០ | ចម្ការស្រល់ | ៣.៧១០ | ០,០២ | ៣.៨៧០ | ០,០២ | ១៦០ | ០,០០ |
| ១១ | ចម្ការឈើដាំ | ៤៤.២៨៩ | ០,២៤ | ៤៣.១២២ | ០,២៤ | -១,១៦៧ | ០,០០ |
| **សរុបផ្ទៃដីគម្របព្រៃឈើ** | | **៨.៥១៨.១៧៣** | **៤៦,៩០** | **៨.១៨១.៩០១** | **៤៥,០៥** | **-៣៣៦,២៧៣** | **-១,៨៥** |
| **សរុបផ្ទៃដីពុំមានគម្របព្រៃឈើ** | | **៩.៦៤២.៥០១** | **៥៣,១០** | **៩.៩៧៨.៧៧៣** | **៥៤,៩៥** | | |
| **ផ្ទៃដីសរុបរួម** | | **១៨.១៦០.៦៧៤** | **១០០** | **១៨.១៦០.៦៧៤** | **១០០** | | |



**រូបភាព៩ :** ផែនទីការប្រែប្រួលធនធានគម្របព្រៃឈើឆ្នាំ២០១៤-២០១៦(កម្មវិធីរេដបូក)

**តារាង៥ :** ស្ថិតិទិន្នន័យការប្រែប្រួលធនធានគម្របព្រៃឈើឆ្នាំ២០០៦-២០១៦ (កម្មវិធីរេដបូក)

| ល.រ | ប្រភេទចំណាត់ថ្នាក់ | ការប្រែប្រួល ២០០៦-២០១០ | | ការប្រែប្រួល ២០១០-២០១៤ | | ការប្រែប្រួល ២០១៤-២០១៦ | | ការប្រែប្រួល ២០០៦-២០១៦ | |
|---|---|---|---|---|---|---|---|---|---|
| | | ហិកតា | ភាគរយ% | ហិកតា | ភាគរយ% | ហិកតា | ភាគរយ% | ហិកតា | ភាគរយ% |
| ១ | ព្រៃស្រោង | -១៣៦,៣៤៦ | -០,៧៥ | -៦០០,០២២ | -៣,៣០ | -១១២.៦៧០ | -០,៦២ | -៨៤៩,០៣៨ | -៤,៦៧ |
| ២ | ព្រៃពាក់កណ្ដាលស្រោង | -៦២,៣២៤ | -០,៣៤ | -២៨២,៧៩៧ | -១,៥៦ | -៣៦.៣៧៣ | -០,២០ | -៣៨១,៤៩៤ | -២,១០ |
| ៣ | ព្រៃល្បោះ | -១១៥,០២០ | -០,៦៣ | -១,០១៧,៨៦៥ | -៥,៦០ | -១៤៤.១៨៣ | -០,៨០ | -១,២៧៧,០៦៨ | -៧,០៣ |
| ៤ | ព្រៃលិចទឹក | -៧៣,៣៥០ | -០,៤០ | -៤២,៩២៧ | -០,២៤ | -៣.២៦៥ | -០,០២ | -១១៩,៥៤២ | -០,៦៦ |
| ៥ | ព្រៃដុះឡើងវិញ | ៣៣,២១៨ | ០,១៨ | -២០,៧៨១ | -០,១១ | -៣១.៧១៨ | -០,១៨ | -១៩,២៨១ | -០,១១ |
| ៦ | ព្រៃឬស្សី | ១,០៩៣ | ០,០១ | -២៥៣ | ០,០០ | -៥,២៨០ | ០,០៣ | -៤,៤៣៩ | -០,០២ |
| ៧ | ព្រៃកោងកាង | -៦១៧ | -០,០១ | ១,៥៥៩ | ០,០១ | ១,៧៧៦ | ០,០១ | -៨៣៤ | -០,០១ |
| ៨ | ព្រៃស្នាច់ | -១៤៨ | ០,០០ | -១,៤៦៤ | -០,០១ | ០ | -០,០០ | -១,៦១៣ | -០,០១ |
| ៩ | ព្រៃស្រល់ | ០ | ០,០០ | ០ | ០,០១ | -១ | ០,០០ | ៣៨ | ០,០១ |
| ១០ | ចម្ការស្រល់ | ១១ | ០,០០ | ៣,៦៩៩ | ០,០២ | ១៦០ | ០,០០ | ៣,៨៧០ | ០,០២ |
| ១១ | ចម្ការឈើដាំ | -២៦,៣៣៣ | -០,១៥ | ២៧,០៧៤ | ០,១៥ | -១,១៦៧ | ០,០០ | -៤២៥ | ០,០០ |
| | **សរុបផ្ទៃដីគម្របព្រៃឈើ** | **-៣៧៩,៨១៥** | **-២,០៩** | **-១,៩៣៣,៧៣៨** | **-១០,៨៥** | **-៣៣៦,២៧៣** | **-១,៨៥** | **-២,៦៤៩,៨២៦** | **-១៤,៥៩** |




**រូបភាព១០** : កាប្រែប្រួលគម្របព្រៃឈើឆ្នាំ២០០៦-២០១៦ (កម្មវិធីរេដបូក)

យោងតាមក្រាហ្វិកខាងលើឃើញថា អត្រាប្រែប្រួលធនធានគម្របព្រៃឈើក្នុងអំឡុងឆ្នាំ ២០០៦-២០១០ មានប្រមាណ២,០៩% ដោយគិតជាមធ្យមប្រចាំឆ្នាំ ០,៥២% ធៀបនឹងផ្ទៃដីប្រទេស ក៏ប៉ុន្តែអត្រានៃការប្រែប្រួលនេះមានការកើនឡើងខ្លាំង ចាប់ពីឆ្នាំ២០១០-២០១៤ មានប្រមាណ ១០,៦៥% ដោយគិតជាមធ្យមប្រចាំឆ្នាំ ២,៦៦% ធៀបនឹងផ្ទៃដីប្រទេស។

ដោយឡែកតាមការធ្វើបច្ចុប្បន្នភាពធនធានគម្របព្រៃឈើឆ្នាំ២០១៦ បង្ហាញថាអត្រាប្រែប្រួលក្នុងអំឡុងឆ្នាំ២០១៤-២០១៦ មានប្រមាណ១,៨៥% ដោយគិតជាមធ្យមប្រចាំឆ្នាំ ០,៩៣% ធៀបនឹងផ្ទៃដីប្រទេស លទ្ធផលនេះបង្ហាញឱ្យឃើញថា អត្រាបាត់បង់ធនធានគម្របព្រៃឈើទាបជាងអំឡុងឆ្នាំ២០១០-២០១៤ កន្លងមក មូលហេតុដោយសារប្រសិទ្ធភាពនៃការអនុវត្តកំណែទម្រង់លើការគ្រប់គ្រងព្រៃឈើរបស់រាជរដ្ឋាភិបាល ក៏ដូចជាការចូលរួមទប់ស្កាត់បទល្មើសព្រៃឈើពីសហគមន៍មូលដ្ឋាន កងកំលាំងប្រដាប់អាវុធ និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់។

## ៣.៣ ការប្រែប្រួលធនធានគម្របព្រៃឈើជាតិឆ្នាំ១៩៦៥-២០១៦

ប្រទេសកម្ពុជាបានធ្វើការវាយតម្លៃធនធានគម្របព្រៃឈើជាតិចាប់ពីឆ្នាំ ១៩៦៥ រហូតដល់បច្ចុប្បន្នបានចំនួន៨លើក។ ការវាយតម្លៃនេះធ្វើឡើងជាដំណាក់កាលខុសៗគ្នា ដោយក្នុងអំឡុងឆ្នាំ ១៩៦៥ ដល់១៩៩២/៩៣ មានរយៈពេល២៧ឆ្នាំដោយសារប្រទេសកម្ពុជាធ្លាក់ក្នុងសង្គ្រាមស៊ីវិលអូសបន្លាយជិត៣ទសវត្សរ៍ នឹងបានដាក់សម្ពាធដ៏ធ្ងន់ធ្ងរទៅលើការប្រើប្រាស់ធនធានព្រៃឈើ ដូចនេះទើបចាប់ពីឆ្នាំ១៩៩៣រហូតដល់ឆ្នាំ២០១៤ ការវាយតម្លៃជាមធ្យមមានរយៈពេល៤ឆ្នាំម្តង។ ជាងនេះទៀត បច្ចុប្បន្នប្រទេសកម្ពុជាបានចូលរួមអនុវត្តកម្មវិធីរេដបូកជាមួយសហគមន៍អន្តរជាតិ ដែលទិន្នន័យគម្របព្រៃឈើកាន់តែមានសារៈសំខាន់ឡើង សម្រាប់ធ្វើការរៀបចំផែនការគ្រប់គ្រងធនធាន

ធម្មជាតិ និងគាំទ្រដល់ដំណើរការត្រួតពិនិត្យ តាមដាន និងវាយតម្លៃធនធានគម្របព្រៃឈើសម្រាប់អនុវត្តកម្មវិធីរេដបូកកម្ពុជា បានធ្វើការវាយតម្លៃគម្របព្រៃឈើជារៀងរាល់២ឆ្នាំម្តង។




**រូបភាព១១ :** ក្រាហ្វិកអត្រាការប្រែប្រួលធនធានគម្របព្រៃឈើឆ្នាំ១៩៦៥-២០១៦

តាមរយៈលទ្ធផលក្នុងក្រាហ្វិកខាងលើបង្ហាញថា អត្រាប្រែប្រួលធនធានគម្របព្រៃឈើក្នុងអំឡុងឆ្នាំ១៩៦៥-២០១៦ មានការថយចុះប្រមាណ ២៤,៩% ធៀបនឹងផ្ទៃដីប្រទេស។ កត្តាជាច្រើនដែលធ្វើឱ្យអត្រាធនធានគម្របព្រៃឈើនេះថយចុះរួមមាន សង្គ្រាមស៊ីវិល កំណើនប្រជាជន តម្រូវការដីកសិកម្ម និងកត្តាចម្បងៗផ្សេងទៀតផងដែរ។




**រូបភាព១២ :** ផែនទីការប្រែប្រួលធនធានគម្របព្រៃឈើជាតិឆ្នាំ២០០៦-២០១៦(ព្រៃឈើជាតិ)




**រូបភាព១៣ :** ផែនទីការប្រែប្រួលធនធានគម្របព្រៃឈើជាតិឆ្នាំ២០០៦-២០១៦(កម្មវិធីរេដបូក)

# ជំពូកទី ៤
## សន្និដ្ឋាន

ការវាយតម្លៃធនធានគម្របព្រៃឈើឆ្នាំ២០១៦ រៀបចំផលិតដោយក្រុមការងារបច្ចេកទេសជាតិ (GDANCP/MoE, FA/MAFF, FIA/MAFF) និងត្រួតពិនិត្យផ្នែកបច្ចេកទេសដោយអ្នកជំនាញការអន្តរជាតិ FAO-UNREDD, JICA-CAMREDD និងសាកលវិទ្យាល័យអន្តរជាតិនានា។ ជាលទ្ធផលធនធានគម្របព្រៃឈើជាតិឆ្នាំ២០១៦ បានបង្ហាញថាធនធានគម្របព្រៃឈើមានប្រមាណ **៨.៧៤២.៤០១ហិកតា** ស្មើនឹង **៤៨,១៤%** ធៀបនឹងផ្ទៃដីសរុបទូទាំងប្រទេស និងមានអត្រាបាត់បង់ចាប់ពីអំឡុងឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦ ជាមធ្យមប្រចាំឆ្នាំប្រមាណ០,៦៧% ស្មើនឹងផ្ទៃដី **១២១,៣២៨ ហិកតា** ធៀបនឹងផ្ទៃដីប្រទេស។

តាមការព្យាករណ៍ទុក នៅរយៈពេល២ឆ្នាំខាងមុខទៀតអត្រានៃការបាត់បង់គម្របព្រៃឈើនេះ នឹងមានការកាត់បន្ថយជាបន្តទៀត អាស្រ័យដោយសារប្រសិទ្ធភាពនៃការអនុវត្តកំណែទម្រង់លើការគ្រប់គ្រង និងអភិរក្ស តំបន់ការពារធម្មជាតិរបស់រាជរដ្ឋាភិបាល ក៏ដូចជាការចូលរួមពីសហគមន៍មូលដ្ឋានពីកំលាំងប្រដាប់អាវុធ និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ក្នុងការទប់ស្កាត់បទល្មើសព្រៃឈើ។ ក្នុងន័យនេះក្រសួងបរិស្ថាននឹងបន្តភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនក៏ដូចជាសហការជាមួយស្ថាប័ន ដៃគូអភិវឌ្ឍន៍ ភាគីពាក់ព័ន្ធនានាក្នុងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ អភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាពដើម្បីនិរន្តរភាព បរិស្ថាន និងធនធានធម្មជាតិ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១: និយមន័យព្រៃឈើ

**ព្រៃឈើជាតិ** "ព្រៃឈើ គឺជាប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិ ឬសិប្បនិមិត្ត ក្រោមទម្រង់ជាដីសើម ដីលិចទឹក ឬដីស្ងួត ដែលគ្របដណ្តប់ដោយរុក្ខជាតិ ដុះដោយធម្មជាតិ ឬដាំ មានកម្ពស់ចាប់ពី ៥ម៉ែត្រឡើងទៅ ផ្ទៃដីលើសពី ០,៥ហិកតា និងមានកម្រិតគ្របដណ្តប់របស់កន្សោមស្លឹកលើសពី ១០%។ ចម្ការឈើដាំ ដូចជាកៅស៊ូ ដូងប្រេង អាកាស្យា ម៉ៃសាក់ ប្រេងខ្យល់ និងប្រភេទរុក្ខជាតិផ្តល់ឈើដទៃទៀត ដែលមានលក្ខណៈដូចរៀបរាប់ខាងលើក៏ត្រូវបានចាត់ចូលជាព្រៃដែរ" ។

**កម្មវិធីរេដបូក** ព្រៃឈើ ដែលជាកម្មវត្ថុនៃការអនុវត្តកម្មវិធីរេដបូក (REDD+) សំដៅលើឯកតា នៃប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិ ឬសិប្បនិមិត្តក្រោមទម្រង់ជាដីសើម ដីលិចទឹក ឬដីស្ងួត ដែលគ្របដណ្តប់ដោយរុក្ខជាតិដុះដោយធម្មជាតិ ឬដាំ មានទំហំផ្ទៃដីលើសពី ០,៥ហិកតា និងមានកម្ពស់ដើមឈើចាប់ពី៥ម៉ែត្រ និងមានកម្រិតគម្របកន្សោមស្លឹកលើសពី១០%។ ត្រូវបានចាត់បញ្ចូលទៅក្នុងតំបន់អនុវត្តកម្មវិធីរេដបូក(REDD+) ផងដែរ នូវផ្ទៃដីព្រៃរេចរឹល ព្រៃដាំ ឬផ្ទៃដីដែលមានដំណុះឈើ ឬតំបន់ស្តារព្រៃឈើឡើងវិញ។ ចំពោះចម្ការកៅស៊ូ ដូងប្រេង ស្វាយចន្ទី និងចម្ការឈើហូបផ្លែដទៃទៀតមិនត្រូវបានចាត់បញ្ចូលទៅក្នុងនិយមន័យក្នុងកម្មវិធីរេដបូក(REDD+) ឡើយ។

**ឧបសម្ព័ន្ធ២**: តារាងចំណាត់ថ្នាក់ធនធានគម្របព្រៃឈើឆ្នាំ២០១៦

| **ល.រ** | **ចំណាត់ថ្នាក់** | **បរិយាយ** |
|---|---|---|
| ១ | ព្រៃស្រោង | ជាព្រៃមានច្រើនស្រទាប់ដែលដើមឈើរក្សានូវស្លឹករបស់វាពេញមួយឆ្នាំ។ ព្រៃប្រភេទនេះ រួមបញ្ចូលទាំងព្រៃតំបន់ទំនាប ត្រូពិច ព្រៃបៃតងតំបន់ភ្នំ ព្រៃបៃតងស្ងួត និងព្រៃនៅតាមមាត់ស្ទឹង ទន្លេ។ |
| ២ | ព្រៃពាក់កណ្តាលស្រោង | ជាការបញ្ចូលគ្នានៃប្រភេទព្រៃស្រោង និងប្រភេទឈើព្រៃល្បោះហើយ ភាគរយនៃព្រៃ ស្រោងប្រែប្រួលពី៣០% ទៅ ៧០%។ ព្រៃពាក់កណ្តាលស្រោង បន្តមានពណ៌បៃតង ពេញមួយឆ្នាំ ទោះបីជាអត្រាភាគរយនៃប្រភេទ ព្រៃល្បោះខ្ពស់ក៏ដោយ។ |
| ៣ | ព្រៃល្បោះ | រួមបញ្ចូលព្រៃល្បោះចម្រុះស្ងួត ( Dry mixed Deciduous forest ) និងប្រភេទព្រៃDipterocarp ស្ងួត |
| ៤ | ព្រៃឬស្សី | ជាប្រភេទព្រៃដែលគ្របដណ្តប់ដោយឬស្សី |
| ៥ | ព្រៃគុម្ពោត | រួមបញ្ចូលព្រៃគុម្ពោតបៃតងជានិច្ច និងព្រៃគុម្ពោតស្ងួត |
| ៦ | ព្រៃកោងកាង | រួមបញ្ចូលទាំងព្រៃកោងកាងក្រាស់ និងស្តើង |
| ៧ | ព្រៃស្នាច់ | ជាប្រភេទព្រៃដែលសំបូរដោយដើមស្នាច់ និងដុះនៅលើទឹកភ្លាវ |
| ៨ | ចម្ការកៅស៊ូ | ចម្ការកៅស៊ូជាលក្ខណៈគ្រួសារ និងឧស្សាហកម្ម |
| ៩ | ព្រៃលិចទឹក | ជាប្រភេទព្រៃដែលលិចទឹកនៅរដូវវស្សា និងនៅតំបន់ខ្លះលិចទឹកពេញមួយ ឆ្នាំ ។ ឧទាហរណ៍ដើមរាំងទឹក |
| ១០ | ព្រៃដុះឡើងវិញ | ជាដីព្រៃរេចរិលរងការកាប់ឆ្ការធ្វើជាចម្ការពនេចរពីអតីតកាល និងមានដំណុះឈើដុះឡើងវិញ |
| ១១ | ព្រៃស្រល់ | ជាប្រភេទព្រៃដែលមានរួមបញ្ចូលទាំងប្រភេទស្រល់ស្លឹក២ និងស្លឹក៣ដែលដុះដោយធម្មជាតិ |
| ១២ | ចម្ការស្រល់ | ចម្ការឈើដែលដាំប្រភេទប្រេងខ្យល់ស្លឹក២ និងស្លឹកបី |
| ១៣ | ចម្ការដូងប្រេង | ចម្ការដូងប្រេង |
| ១៤ | ចម្ការឈើដាំ | ចម្ការប្រេងខ្យល់ ចម្ការអាកាស្យា ចម្ការមៃសាក់ និងចម្ការឈើផ្សេងៗ ដែលរាប់បញ្ចូលជា |
| ១៥ | ដីស្រែ | រាប់បញ្ចូលទាំងដីស្រែតំបន់ខ្ពង់រាប ទំនាប និងស្រូវឡើងទឹក |
| ១៦ | ចម្ការ | ចម្ការដំឡូង ចម្ការស្វាយចន្ទី ចម្ការស្វាយហូបផ្លែ ចម្ការដូង ចម្ការម្រេច ចម្ការដំណាំហូប ផ្លែ |
| ១៧ | ដីវាលឬខ្សាច់ | ដីវាលដែលបានឈូសឆាយហើយសម្រាប់បម្រើដល់ការសាងសង់ ផ្លូវលំនឹងរួមបញ្ចូលទាំងវាលខ្សាច់នៅតាមដងស្ទឹងទន្លេ |
| ១៨ | ភូមិ | ជាបណ្តុំផ្ទះ និងមានលាយដំណាំជុំវិញផ្ទះ |
| ១៩ | ទីប្រជុំជន | ទីក្រុង និងទីប្រជុំជនដែលមានសំណង់រឹងមាំ |
| ២០ | ថ្ម | ទីតាំងវាយថ្ម និងវាលថ្មជាលក្ខណៈធម្មជាតិ |
| ២១ | វាលស្មៅ | រាប់បញ្ចូលទាំងវាលស្មៅជាលក្ខណៈធម្មជាតិ និងសិប្បនិមិត្ត |
| ២២ | ផ្ទៃទឹក | រួមបញ្ចូលផ្ទៃទឹកទន្លេ សមុទ្រ និង បឹង |

# ឧបសម្ព័ន្ធ៣: ទិន្នន័យធនធានគម្របព្រៃឈើជាតិតាមបណ្តាខេត្តឆ្នាំ២០១៦

| ឈ្មោះខេត្ត | ផ្ទៃដីគម្របព្រៃឈើ | | | | | សរុបផ្ទៃដីពុំមានគម្របព្រៃឈើ (ហ.ត) | សរុបរួម (ហ.ត) |
|---|---|---|---|---|---|---|---|
| | ព្រៃស្រោង | ព្រៃពាក់កណ្តាលស្រោង | ព្រៃល្បោះ | ព្រៃផ្សេងៗ | សរុបផ្ទៃដីព្រៃឈើ(ហ.ត) | | |
| បន្ទាយមានជ័យ | ១.៤៦០ | ២.៨៦០ | ៩.៤៣៧ | ៨.០៥១ | ២១.៨០៨ | ៥៩៣.០១១ | ៦១៤.៨១៩ |
| បាត់ដំបង | ៥៩.៤៨៣ | ១៦.៣៨២ | ២០.០៧៥ | ១៧១.៥៧៣ | ២៦៧.៥១៣ | ៩១៩.៦៩៧ | ១.១៨៧.២១០ |
| កំពង់ចាម | ៦៥៨ | ៥៩ | ៦៤១ | ៥០.៩២៣ | ៥២.២៨១ | ៤០២.៨៩៣ | ៤៥៥.១៧៤ |
| កំពង់ឆ្នាំង | ១៧.៣១៩ | ៥.៤១៤ | ៧១.៩១៣ | ៤៧.០១៨ | ១៤១.៦៦៤ | ៣៨៧.៧៩៧ | ៥២៩.៤៦១ |
| កំពង់ស្ពឺ | ៦៤.៥៨៧ | ២១.៦៧៧ | ១៣០.០៦៥ | ១៩.១៧៨ | ២៣៥.៥០៧ | ៤៦០.៩៦៤ | ៦៩៦.៤៧១ |
| កំពង់ធំ | ១៩៤.២៥១ | ១៤.៨៥០ | ៤៥.៩៤៨ | ២២៤.៦៤០ | ៤៧៩.៦៨៩ | ៧៦៥.០៧៤ | ១.២៤៤.៧៦៣ |
| កំពត | ១២៥.៧៦៤ | ៣.៩២៤ | ២៧.៧៥៨ | ៤.៩៧០ | ១៦២.៤១៦ | ៣០៩.៣៩៩ | ៤៧១.៨១៥ |
| កណ្តាល | ០ | ០ | ៩៩ | ១៤.៦៤៤ | ១៤.៧៤៣ | ៣៤១.៦៣០ | ៣៥៦.៣៧៣ |
| កែប | ១.៨០៦ | ៩ | ០ | ១.២០១ | ៣.០១៦ | ១២.១៥៧ | ១៥.១៧៣ |
| កោះកុង | ៨៣៩.៩៣៨ | ១១.៦៣២ | ២៤.៤០៤ | ៩៥.២៤៧ | ៩៧១.២២១ | ២៤០.៣៧៤ | ១.២១១.៥៩៥ |
| ក្រចេះ | ១០០.២៣៩ | ៩៥.៣៦៤ | ៤០៣.០៥៥ | ១៣៦.៤១០ | ៧៣៥.០៦៨ | ៤៦២.២៣៧ | ១.១៩៧.៣០៥ |
| មណ្ឌលគីរី | ១៣១.៤៣៩ | ២១២.៣៤១ | ៨០៣.៦៦៥ | ៦៧.៩៧៥ | ១.២១៥.៤២០ | ១៥១.៤៧២ | ១.៣៦៦.៨៩២ |
| ឧត្តរមានជ័យ | ៥០.០៥១ | ១៨.៦៣៩ | ១០៤.៩១២ | ១៦.៣៦១ | ១៨៩.៩៦៣ | ៤៧៣.២០២ | ៦៦៣.១៦៥ |
| ប៉ៃលិន | ២៩.៨៧៧ | ១.៤៥៤ | ៥០៣ | ៥១០ | ៣២.៣៤៤ | ៧៥.៣៦៧ | ១០៧.៧១១ |
| ភ្នំពេញ | ០ | ០ | ០ | ០ | ០ | ៣៧.៣៧៤ | ៣៧.៣៧៤ |
| ព្រះសីហនុ | ៤៨.៩០១ | ២.៥៧៩ | ២ | ២៩.៤៣២ | ៨០.៩១៤ | ៦៨.២៩១ | ១៤៩.២០៥ |
| ព្រះវិហារ | ២១១.៧៣៧ | ១៤១.៨៣៦ | ៦៩៨.៨៨០ | ៤២.០១៩ | ១.០៩៤.៤៧២ | ៣០៨.៦១៥ | ១.៤០៣.០៨៧ |
| ព្រៃវែង | ១៩ | ០ | ៩២ | ១.៦១៣ | ១.៧២៤ | ៤៧៤.៤៣៦ | ៤៧៦.១៦០ |
| ពោធិ៍សាត់ | ៤៤០.៥២៨ | ៧៣.១៥៧ | ១៣៨.៣០៩ | ៧៥.៦២៥ | ៧២៧.៦១៩ | ៤៣០.៩៧២ | ១.១៥៨.៥៩១ |
| រតនគីរី | ២៣៤.៧៧៦ | ១៧៣.៨២៤ | ៣៣៤.៥៥៥ | ១៥០.៧៦៣ | ៨៩៣.៩១៨ | ២៨៤.៥៤២ | ១.១៧៨.៤៦០ |
| សៀមរាប | ៤៤.៦៦២ | ២៣.០១៨ | ១១៧.៦៧៩ | ១៣៤.៣៥៨ | ៣១៩.៧១៧ | ៧៣៤.៧៣២ | ១.០៥៤.៤៤៩ |
| ស្ទឹងត្រែង | ២៦១.២៤០ | ២៥២.៧៧៩ | ៣៩៥.១១៧ | ៦២.១៨១ | ៩៧១.៣១៧ | ២៣០.៣៤៤ | ១.២០១.៦៦១ |
| ស្វាយរៀង | ២៨ | ០ | ០ | ៥.១៨៩ | ៥.២១៧ | ២៨១.៦០៨ | ២៨៦.៨២៥ |
| តាកែវ | ១.៩១៦ | ០ | ៩.១១៥ | ២.៥៨៤ | ១៣.៦១៥ | ៣៣៥.៤២៨ | ៣៤៩.០៤៣ |
| ត្បូងឃ្មុំ | ៥៥៤ | ១៤៩ | ១២៥ | ១០៨.៨៤៤ | ១០៩.៦៧២ | ៣៨៣.៤៥០ | ៤៩៣.១២២ |
| ទន្លេសាប | ០ | ០ | ០ | ១.៥៦៣ | ១.៥៦៣ | ២៥៣.២០៧ | ២៥៤.៧៧០ |
| ផ្ទៃដីសរុប(ហ.ត) | ២.៨៦១.២៣៣ | ១.០៧១.៩៤៧ | ៣.៣៣៦.៣៤៩ | ១.៤៧២.៨៧២ | ៨.៧៤២.៤០១ | ៩.៤១៨.២៧៣ | ១៨.១៦០.៦៧៤ |
| ភាគរយ (%) | ១៥,៧៦ | ៥,៩០ | ១៨,៣៧ | ៨,១១ | ៤៨,១៤ | ៥១,៨៦ | ១០០ |

**ឧបសម្ព័ន្ធ៤**: ទិន្នន័យបម្រែបម្រួលប្រភេទព្រៃចន្លោះឆ្នាំ២០១៤-២០១៦

| | Forest Type | Year 2016 | | | | | | | | | | | | Total | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | E | Se | D | B | Ff | Fr | M | Mr | P | Pp | Tp | NF | Ha | % |
| Year 2014 | E | 2859768 | 86 | 187 | 85 | | 34 | | 3 | 2 | 13 | 358 | 113367 | 2973903 | 16.4% |
| | Se | 97 | 1070718 | 553 | 181 | | 22 | | | | 1 | 126 | 36622 | 1108320 | 6.1% |
| | D | 134 | 301 | 3329012 | 61 | | 30 | | | | | 2224 | 148770 | 3480532 | 19.2% |
| | B | 45 | 12 | 34 | 124194 | | | | | | | | 6391 | 130678 | 0.7% |
| | Ff | 0 | | | | 470316 | | | | | | | 10762 | 481078 | 2.6% |
| | Fr | 288 | 22 | 254 | 217 | 1 | 186494 | | 192 | | | 122 | 40970 | 228560 | 1.3% |
| | M | 3 | | 36 | | | 2 | 30865 | 836 | | | | 1260 | 33002 | 0.2% |
| | Mr | 1 | | | | | | 123 | 24661 | | | | 1121 | 25906 | 0.1% |
| | P | 2 | | | | | | | | 8193 | | | 1 | 8196 | 0.0% |
| | Pp | | | | | | | | | | 3632 | | 111 | 3743 | 0.0% |
| | Tp | 1 | | 4 | | | 2 | | | | | 39281 | 5001 | 44289 | 0.2% |
| | NF | 894 | 808 | 6269 | 660 | 7494 | 10258 | 238 | 214 | | 224 | 1011 | 9614397 | 9642467 | 53.1% |
| Total | Ha | 2861233 | 1071947 | 3336349 | 125398 | 477813 | 196842 | 31226 | 25906 | 8195 | 3870 | 43122 | 9978773 | 1816067 | 100% |
| | % | 15.8% | 5.9% | 18.4% | 0.7% | 2.6% | 1.1% | 0.2% | 0.1% | 0% | 0% | 0.2% | 54.9% | 100% | 100% |

# ឯកសារយោង

- ក្រសួងបរិស្ថាន
  កម្រងទិន្នន័យបម្រែបម្រួលធនធានគម្របព្រៃឈើនៃប្រព័ន្ធតំបន់ការពារ ធម្មជាតិ ឆ្នាំ២០០៦ ២០១៦
- រដ្ឋបាលព្រៃឈើ ធនធានគម្របព្រៃឈើកម្ពុជាឆ្នាំ២០១៤
- ក្រសួងបរិស្ថាន សទ្ធានុក្រមការប្រែប្រួលអាកាសធាតុ ២០១៧
- ក្រសួងបរិស្ថាន កម្រិតយោងព្រៃឈើឆ្នាំ២០១៦